**EMBASSY OF JAPAN**
**IN THE KINGDOM OF CAMBODIA**

# PRESS RELEASE

No. 22 PR-24/EoJ 21 June 2024

## Japan Provides US$479,018 for Eliminating Violence against Children in Schools

The Government of Japan will provide US$479,018 for a recipient organizations under the framework, *the Grant Assistance for Japanese NGO Projects*. The Grant Contract was signed today between H.E. Mr. UENO Atsushi, Ambassador Extraordinary and Plenipotentiary of Japan to the Kingdom of Cambodia, and the representative of recipient, to carry out the following projects:

'Eliminate Violence Against Children in Schools in Kampong Cham, Cambodia (Year 3)' (US$479,018)
Recipient: Save the Children Japan (SCJ)

In this project, Save the Children Japan will implement awareness-raising activities toward children, parents and school officials, establish School-Based Child Protection Systems (SBCPM) and advocate for school-based child protection, with the aim of eliminating violence against children in schools. Through this project, students and teachers of the targeted 43 public schools in Kong Meas district, Kampong Cham province will be able to benefit from safer and more inclusive violence-free environment, which will lead to an improvement in healthy development and well-being of children.

*The Grant Assistance for Japanese NGO Projects* started in Cambodia in 2002 to support activities by Japanese NGOs to help Cambodia's reconstruction and development efforts at the grassroots level. Since 2002, the Government of Japan has provided over US$56 million for 160 projects, mainly in the field of primary education, health, agriculture and mine clearance in Cambodia.

---

*Embassy of Japan in the Kingdom of Cambodia*
*Tel: 023-217-161*
*Email: eco.jpn@pp.mofa.go.jp*
*Website: http://www.kh.emb-japan.go.jp*

**ស្ថានទូតជប៉ុន**
**ប្រចាំព្រះរាជាណាចក្រកម្ពុជា**
**សេចក្តីប្រកាសព័ត៌មាន**

លេខ. 22 PR-24/EoJ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៤

# ជប៉ុនផ្តល់ថវិកា ៤៧៩,០១៨ ដុល្លារអាមេរិក សម្រាប់ការលុបបំបាត់អំពើហិង្សាលើកុមារនៅតាមសាលារៀន

រដ្ឋាភិបាលជប៉ុន នឹងផ្តល់ថវិកាសរុបចំនួន **៤៧៩,០១៨ ដុល្លារអាមេរិក** ដល់អង្គភាពទទួលជំនួយមួយ ក្រោមគ្រោងការណ៍ជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយ **ឯកឧត្តម អ៊ូអិណុ អាត់ស៊ូស៊ី** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងអ្នកតំណាងស្ថាប័នទទួលជំនួយ សម្រាប់អនុវត្តគម្រោងខាងក្រោម៖

**<u>គម្រោងលុបបំបាត់អំពើហិង្សាលើកុមារនៅតាមសាលារៀនក្នុងខេត្តកំពង់ចាម ប្រទេសកម្ពុជា (ឆ្នាំទី ៣) (ថវិកាចំនួន ៤៧៩,០១៨ ដុល្លារអាមេរិក)</u>**

**<u>ស្ថាប័នទទួលជំនួយ៖ អង្គការ Save the Children Japan (SCJ)</u>**

នៅក្នុងគម្រោងនេះ អង្គការ Save the Children Japan នឹងអនុវត្តសកម្មភាពលើកកម្ពស់ការយល់ដឹងដល់កុមារ ឪពុកម្តាយ និងបុគ្គលិកអប់រំ បង្កើតប្រព័ន្ធការពារកុមារនៅតាមសាលារៀន (SBCPM) និងតស៊ូមតិដើម្បីកិច្ចការពារកុមារនៅតាមសាលារៀន ក្នុងគោលបំណងលុបបំបាត់អំពើហិង្សាលើកុមារនៅតាមសាលារៀន។ តាមរយៈគម្រោងនេះ សិស្ស និងគ្រូបង្រៀន នៃសាលារៀនគោលដៅចំនួន៤៣ ក្នុងស្រុកកងមាស ខេត្តកំពង់ចាម នឹងអាចទទួលបានអត្ថប្រយោជន៍ពីបរិស្ថានដែលគ្មានអំពើហិង្សា មានសុវត្ថិភាព និងមានលក្ខណៈបរិយាបន្នជាងមុន ដែលនឹងនាំឱ្យមានភាពប្រសើរឡើងនូវការលូតលាស់ប្រកបដោយសុខភាពល្អ និងសុខុមាលភាពរបស់កុមារ។

ជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន បានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ២០០២ ដើម្បីគាំទ្រដល់សកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ក្នុងកិច្ចខិតខំប្រឹងដើម្បីជួយដល់ការអភិវឌ្ឍ និងស្តាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកម្រិតមូលដ្ឋាន។ ចាប់តាំងពី

ឆ្នាំ២០០២ មក រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង ៥៦លាន ដុល្លារអាមេរិក ដល់គម្រោងចំនួន ១៦០ ដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតបឋមសិក្សា វិស័យសុខាភិបាល វិស័យកសិកម្ម និងសកម្មភាពបោសសម្អាតមីនក្នុងប្រទេសកម្ពុជា។

---


ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

ទូរសព្ទ៖ ០២៣-២១៧-១៦១

អ៊ីម៉ែល៖ eco.jpn@pp.mofa.go.jp

គេហទំព័រ៖ *http://www.kh.emb-japan.go.jp*

ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៤

នៅថ្ងៃទី២១ ខែមិថុនា កិច្ចសន្យាផ្តល់ជំនួយរបស់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុនត្រូវបានចុះហត្ថលេខា។ ដោយសារកាលៈទេសៈរបស់ស្ថានទូតជប៉ុន និងស្ថាប័នទទួលជំនួយ ភាគីទាំងពីរបានចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយ និងឯកសារពាក់ព័ន្ធដាច់ដោយឡែកពីគ្នា។

ជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន ដែលហៅថា "អ៊ិនរ៉េន" បានចាប់ផ្តើមតាំងពីឆ្នាំ២០០២ ដើម្បីគាំទ្រដល់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ក្នុងការអនុវត្តគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមរបស់ពួកគេនៅក្នុងប្រទេស ឬតំបន់កំពុងអភិវឌ្ឍ។ ក្នុងរយៈពេល២០ឆ្នាំចុងក្រោយនេះ ស្ថានទូតជប៉ុនបានផ្តល់ជំនួយជាង ១៦០គម្រោង នៅក្នុងប្រទេសកម្ពុជាតាមរយៈកម្មវិធីនេះ ហើយគម្រោងទាំងនេះបានចូលរួមចំណែកដោយផ្ទាល់ក្នុងការកែលម្អគុណភាពជីវិតរបស់ប្រជាជនកម្ពុជា។

សេចក្តីសង្ខេបអំពីគម្រោងដែលចុះហត្ថលេខានាថ្ងៃនេះមានដូចតទៅ។

អង្គការ Save the Children Japan (SCJ)

គម្រោងលុបបំបាត់អំពើហិង្សាលើកុមារនៅតាមសាលារៀនក្នុងខេត្តកំពង់ចាម ប្រទេសកម្ពុជា (ឆ្នាំទី៣)

ខ្ញុំសូមជម្រាបជូនដោយសង្ខេបនូវគម្រោងដែលយើងបានចុះហត្ថលេខានាថ្ងៃនេះ៖

រដ្ឋាភិបាលជប៉ុននឹងផ្តល់ថវិកាចំនួន ៤៧៩.០១៨ ដុល្លារអាមេរិក សម្រាប់គម្រោងដែលអនុវត្តដោយអង្គការ Save the Children Japan។

ចាប់តាំងពីឆ្នាំ២០២២មក អង្គការ Save the Children Japan បាននិងកំពុងអនុវត្តគម្រោងតាមរយៈជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន នៅសាលារដ្ឋចំនួន៤៣ ក្នុងខេត្តកំពង់ចាម៖ អង្គការមានបំណងលុបបំបាត់អំពើហិង្សាលើកុមារ ដូចជាការដាក់ទណ្ឌកម្មលើរាងកាយ ការធ្វើបាប និងការប្រើប្រាស់ភាសារំលោភបំពាន។ នៅក្នុងគម្រោងនេះ អង្គការនឹងបង្កើតប្រព័ន្ធការពារអំពើហិង្សាលើកុមារ និងប្រព័ន្ធស្វែងរក ក៏ដូចជាដោះស្រាយអំពើហិង្សាលើកុមារ នៅក្នុងសាលារៀន ដោយចងក្រងឯកសារអំពីឧទាហរណ៍ និងមេរៀនល្អៗមួយចំនួន ទាក់ទងនឹងយន្តការការពារកុមារនៅក្នុងសាលារៀន និងការពង្រឹងប្រព័ន្ធនាពេលបច្ចុប្បន្ន សម្រាប់យន្តការការពារកុមារតាមសង្កាត់។ តាមរយៈសកម្មភាពទាំងនេះ ខ្ញុំសង្ឃឹមថាកុមារនឹងទទួលបានអត្ថប្រយោជន៍ពីបរិស្ថានដែលគ្មានអំពើហិង្សា មានសុវត្ថិភាព និងមានលក្ខណៈបរិយាបន្នជាងមុន ដែលនឹងនាំឱ្យមានភាពប្រសើរឡើងសម្រាប់ការលូតលាស់ និងសុខុមាលភាពរបស់កុមារ។

ខ្ញុំមានសេចក្ដីសោមនស្សរីករាយដោយសង្កេតឃើញថានាពេលថ្មីៗនេះ ប្រទេសកម្ពុជាបាននិងកំពុងអភិវឌ្ឍយ៉ាងឆាប់រហ័ស។ ទោះបីជាយ៉ាងណា ខ្ញុំក៏ទទួលស្គាល់ថានៅតែមានបញ្ហាប្រឈមមួយចំនួនដែលត្រូវដោះស្រាយ ដើម្បីកែលម្អគុណភាពជីវិតរបស់ប្រជាជន។ រដ្ឋាភិបាលជប៉ុន នឹងបន្តសហការជាមួយអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិជប៉ុននានា និងគាំទ្រការងាររបស់ពួកគេក្នុងការដោះស្រាយបញ្ហានានា។

ខ្ញុំសូមជូនពរ លោក លោកស្រី មានសុខភាពល្អ សុភមង្គល និង សូមឱ្យមិត្តភាពជប៉ុន-កម្ពុជាកាន់តែរីកចម្រើន។

ស្ថានទូតជប៉ុន

ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

អ៊ូអិណុ អាត់ស៊ូស៊ី